មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការ សេដាក) បានរៀបចំវេទិកាផ្លាស់ប្តូរយោបល់ ស្តីអំពី **"ឱកាស និងការប្រឈមក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មស្រោចស្រពនៅប្រទេសកម្ពុជា"** កាលពីថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៨ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។



សមាសភាពរបស់អ្នកចូលរួមនៅក្នុងវេទិកាផ្លាស់ប្តូរយោបល់នេះ មានចំនួនប្រមាណ ៣០ នាក់ ដែលមានមន្ត្រីជំនាញមកពីមន្ទីរធនធានទឹក និងឧតុនិយម អ្នកដឹកនាំសហគមន៍កសិករប្រើប្រាស់ទឹកតាមបណ្តាខេត្តមួយចំនួន មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល និងតំណាងក្រុមអ្នកផ្តល់ជំនួយនៅក្នុងប្រទេសកម្ពុជា។

វេទិកានេះរៀបចំឡើងក្នុងគោលបំណងបង្ហាញអំពីវិសាលភាព និងស្ថានភាពនៃប្រព័ន្ធធារាសាស្ត្រនៅក្នុងខេត្តចំនួន ១៣ នៅក្នុងប្រទេសកម្ពុជា និងបង្កឱកាសពិភាក្សា ផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមករវាងមន្ត្រីជំនាញមកពីមន្ទីរធនធានទឹក និងឧតុនិយម អ្នកដឹកនាំសហគមន៍កសិករប្រើប្រាស់ទឹកតាមបណ្តាខេត្តមួយចំនួន និងមន្ត្រីអង្គការមិនមែនរាជរដ្ឋាភិបាល ស្តីអំពី ឱកាស និងការប្រឈមរបស់ពួកគេក្នុងការអនុវត្តន៍គំរោងកែលំអប្រព័ន្ធធារាសាស្ត្រ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងស្វែងរកយុទ្ធសាស្ត្រ ដើម្បីធ្វើការអភិវឌ្ឍន៍ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព។